# អ្នកជំនាញចរាចរណ៍បារម្ភថា ពលរដ្ឋពិបាកចាំស្លាកឈ្មោះពិសេស ដែលបិទលើរថយន្ត ពេលបង្កគ្រោះថ្នាក់

*ប្រភព ៖ គេហទំព័រវិទ្យុអាស៊ីសេរី ចុះផ្សាយថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០*

អ្នកជំនាញសុវត្ថិភាពចរាចរណ៍ និងពលរដ្ឋបារម្ភថា ស្លាកលេខឡានពិសេសថ្មី ដែលសរសេរឈ្មោះជាអក្សរឡាតាំង បិទនៅលើរថយន្ត អាចនឹងធ្វើឱ្យពលរដ្ឋពិបាកចាំស្លាកឈ្មោះទាំងនោះ ពេលរថយន្តបង្កគ្រោះថ្នាក់លើដងផ្លូវ ហើយជិះរត់គេច។

ប្រធានវិទ្យាស្ថានសុវត្ថិភាពចរាចរណ៍ លោក គង់ រតនៈ យល់ថា ការបង្កើតឱ្យមានស្លាកពិសេសសម្រាប់រថយន្ត ដែលអាចសរសេរជាឈ្មោះក៏បាននេះ គឺជាយន្តការរកចំណូលចូលរដ្ឋថ្មីមួយទៀត និងជាជម្រើសសម្រាប់អ្នកមានលុយ។ លោកឱ្យដឹងថា មួយថ្ងៃដំបូងនៃការដាក់លក់ស្លាកលេខរថយន្តជាឈ្មោះអក្សរឡាតាំងនេះ ក្រសួងសាធារណការ និងដឹកជញ្ជូន អាចរកចំណូលបានប្រមាណ ៣រយលានរៀល ដែលស្មើប្រមាណ ៧ម៉ឺន ៥ពាន់ ( ៧៥.០០០) ដុល្លារអាមេរិក។

តែអ្វីដែលលោក និងពលរដ្ឋបារម្ភ គឺពលរដ្ឋខ្លះ មិនចេះភាសាអង់គ្លេស ឬភាសាបារាំង នឹងពិបាកចំណាំឈ្មោះស្លាកលេខពិសេស ដែលបង្កគ្រោះថ្នាក់ចរាចរណ៍ ហើយបើករត់គេចខ្លួន។ លោកថា ស្លាកលេខ ឬឈ្មោះពិសេសនេះ អាចជាការបង្កលក្ខណៈងាយស្រួលដល់ជនខិលខូចខ្លះ។ ប៉ុន្តែយ៉ាងណា លោកថា មិនទាន់មានការផ្ដល់យោបល់បែបណាទេ ដោយរង់ចាំមើលការអនុវត្តបន្តិចសិន៖ «*ចាំមើលមួយរយៈ ថាតើការប្រើប្រាស់ស្លាកលេខឯកជនហ្នឹង វាមានផលប៉ះពាល់អ្វីខ្លះ ពីព្រោះខ្ញុំជឿជាក់ថា អ្នកដែលគាត់មានលុយមួយចំនួនហ្នឹង ក៏គាត់មានសីលធម៌ដែរ ហើយបើទោះគាត់ចង់រត់ បើទោះយើងដាក់ស្លាកលេខបែបណា ក៏គាត់គង់តែរត់ដែរ*»។

ក្រសួងសាធារណៈ និងដឹកជញ្ជូន បានដាក់លក់ស្លាកលេខឡាន ដែលអាចកុម្ម៉ង់ ជាឈ្មោះអក្សរឡាតាំងបាន កាលពីថ្ងៃទី៧ មករា។ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន លោក ស៊ុន ចាន់ថុល ថ្លែងប្រាប់អ្នកសារព័ត៌មានពេលសម្ពោធការដាក់លក់ស្លាកលេខរថយន្តនេះថា ជាការបង្កជម្រើសឱ្យពលរដ្ឋតាមចិត្តចង់។ លោកអះអាងថា ពលរដ្ឋមានជម្រើស២ ក្នុងការទិញស្លាកឈ្មោះពិសេសនេះ គឺកុម្ម៉ង់តាមឈ្មោះរបស់ខ្លួន និងការដេញថ្លៃយកឈ្មោះពិសេស។ លោកពន្យល់ថា ការដាក់ឈ្មោះលើស្លាកលេខរថយន្ត គឺយកតាមគំរូប្រទេសផ្សេង ដូចជា ហុងកុង ជាដើម។

លោកអះអាងទៀតថា ម្ចាស់រថយន្ត អាចប្ដូរពីស្លាកលេខ មកស្លាកឈ្មោះបាន ហើយនៅពេលលក់រថយន្ត ម្ចាស់រថយន្តអាចលក់ទាំងស្លាកឈ្មោះ ឬដោះស្លាកទុក លក់តែរថយន្ត ដោយតម្រូវឱ្យទៅបញ្ជាក់នៅក្រសួង ដើម្បីប្ដូរស្លាកឈ្មោះនោះ ទៅដាក់នៅរថយន្តផ្សេង ឬចែកឱ្យតដល់កូនចៅបាន។ ទោះយ៉ាងណា លោក ស៊ុន ចាន់ថុល ថា ក្រសួង នឹងពិនិត្យមើលការស្នើសុំស្លាកឈ្មោះទាំងនោះ ដោយមិនចេញស្លាកឈ្មោះ ដែលមានអត្ថន័យអាសអាភាស ឈ្មោះស្ថាប័នជាតិ ឈ្មោះប្រាសាទ ឬឈ្មោះថ្នាក់ដឹកនាំឡើយ៖ «*ស្លាកលេខពិសេសផ្ទាល់ខ្លួននេះ ដើម្បីផ្ដល់ជម្រើសបន្ថែមទៀត ជូនដល់បងប្អូនយើង ដែលលោកថា លោកចង់បានណាស់ ឈ្មោះកូន ឈ្មោះអ្វីលោកចង់ដាក់ ឱ្យកូន។ អ៊ីចឹងយើងជាអ្នកបម្រើរាស្ត្រ ស្ដាប់សំណូមពររបស់រាស្ត្រ ហើយយកទៅរៀបចំឱ្យមានស្លាកលេខពិសេសផ្ទាល់ខ្លួននេះឯង។ ថវិកាប្រមូលបាននេះ គឺចូលក្នុងថវិកាជាតិ អត់មានមកទេ គឺថា ភ្លាមបញ្ជូនទៅថវិកាជាតិរបស់យើង*»។

នៅក្នុងសន្និសីទកាសែតនោះ លោក ស៊ុន ចាន់ថុល មិនបានបញ្ជាក់ពីក្ដីបារម្ភរបស់ពលរដ្ឋ និងហានិភ័យ ចំពោះជនបង្កគ្រោះថ្នាក់ ហើយបើកបររត់គេច ដោយពលរដ្ឋមិនអាចចំណាំ ស្លាកឈ្មោះនោះបាន។ អាស៊ីសេរី មិនអាចសុំការបញ្ជាក់ចំពោះកង្វល់នេះ ពីក្រុមអ្នកនាំពាក្យទាំង៤នាក់ នៃក្រសួងសាធារណការ និងដឹកជញ្ជូន បានទេ នៅថ្ងៃទី០៩ មករា។ ឯ លោក ស៊ុន ចាន់ថុល ក៏មិនទទួលទូរស័ព្ទដែរ។

ពលរដ្ឋរស់នៅខណ្ឌដង្កោ រាជធានីភ្នំពេញម្នាក់ លោក តារា វិច្ឆ័យ មានបំណងផ្លាស់ប្ដូរស្លាកលេខឡាន ដែលកំពុងជិះសព្វថ្ងៃនេះ ដូរយកស្លាកឈ្មោះពិសេសឡើយ។ លោកថា ស្លាកឈ្មោះនេះ សម្រាប់តែអ្នកមានលុយ មានឡានទំនើបទេ។ តែយ៉ាងណា លោកបារម្ភថា ម្ចាស់រថយន្ត មានផ្លាកពាក់ស្លាកឈ្មោះជាអក្សរឡាតាំង ខិលខូចខ្លះ អាចបុកទ្រព្យសម្បត្តិសាធារណៈ ឬបង្កគ្រោះថ្នាក់ចរាចរណ៍ ហើយពលរដ្ឋ ដែលមិនចេះអានអក្សរឡាតាំង នឹងពិបាកក្នុងការចងចាំ ឬរាយការណ៍ ឱ្យសមត្ថកិច្ច៖ «*ទើបឃើញហ្វេសប៊ុក គេផុសមួយដែរ អីគេ! S.SOLIKA អីគេនោះ។ ឃើញឡានដូចជា ៥៧០ គេដាក់ហ្នឹងដែរ។ បើសម្រាប់ខ្ញុំវិញ គឺប្រហែលជាមានលទ្ធភាព ឬចង់បានស្លាកលេខឈ្មោះអ្វីហ្នឹងទេ។ ពលរដ្ឋ នៅស្រុកខ្មែរយើងវា ពិបាកហ្នឹង ពិបាកហើយ ដោយសារអ្វី ស្រុកខ្មែរយើង ទាក់ទងនឹងធនធានមនុស្ស ក្នុងការចេះដឹងហ្នឹង គាត់នៅមានកម្រិតនៅឡើយ។ ដល់ពេលអ៊ីចឹង ប្រជាពលរដ្ឋ គាត់នៅពិបាកក្នុងស្លាកលេខហ្នឹង*»។

ស្លាកឈ្មោះពិសេសនេះ ត្រូវបានបោះពុម្ពនៅផ្នែកខាងលើ ដោយពាក្យកម្ពុជា ហើយខាងក្រោមពាក្យកម្ពុជាមានអក្សរឡាតាំង ឬបន្ថែមលេខឡាតាំង។ ស្លាកឈ្មោះពិសេសនេះ អាចដាក់បានអក្សរ និងលេខឡាតាំងចំនួន៨ខ្ទង់។ ស្លាកលេខមានប្រព័ន្ធស្កេន (QR Code) នៅផ្នែកខាងស្ដាំ ដើម្បីបញ្ជាក់ព័ត៌មានរបស់រថយន្ត និងម្ចាស់រថយន្ត។

ម្ចាស់រថយន្ត អាចដាក់ពាក្យស្នើសុំទិញ ឬការដាក់ដេញថ្លៃក្នុងស្លាកលេខ ប្រព័ន្ធស្វ័យប្រវត្តិកម្ម ចុះបញ្ជីរថយន្ត តាមរយៈគេហទំព័រ (vehicle.mpwt.gov.kh)។ ស្លាកឈ្មោះកុម្ម៉ង់ពិសេសនេះ មានតម្លៃរហូតដល់ទៅ ៣,៥ ទ្រីលានរៀល៕

**សំណេរ ៖ សម្រាប់អ្នកផ្ទាល់តើអ្នកយល់ស្រប ឬមិនយល់ស្រប ឬមានយោបល់យ៉ាងដូចម្ដេចលើ ស្លាកលេខឈ្មោះពិសេសរថយន្តនេះ ? តើអ្នកគួរចំណាយប្រាក់ដើម្បីទិញស្លាកលេខពិសេសសម្រាប់ខ្លួនដែរឬទេ ? ព្រោះអ្វី ?**




…………………………………………………………………………………………

…………………………………………………………………………………………

…………………………………………………………………………………………

…………………………………………………………………………………………

…………………………………………………………………………………………

…………………………………………………………………………………………

…………………………………………………………………………………………

…………………………………………………………………………………………

…………………………………………………………………………………………

…………………………………………………………………………………………

…………………………………………………………………………………………

…………………………………………………………………………………………

…………………………………………………………………………………………

…………………………………………………………………………………………

…………………………………………………………………………………………